00164702

C11143

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
**Cambodian Defenders Project**
# 12 Street 282, Phnom Penh, Cambodia.
Tel: 023 720032, Fax: 023 720031
www.cdpcambodia.org

ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា
LEGAL AID of CAMBODIA
LAWYERS SERVING CAMBODIA'S POOR FREE OF CHARGE

គោរពជូន អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងព្រហ្មទណ្ឌលេខ : ០០២/១៩-០៩-២០០៧-អ.វ.ត.ក

ដាក់ជូន : អង្គបុរេជំនុំជម្រះ

ថ្ងៃដាក់ : ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨

ភាគីអ្នកដាក់ : មេធាវី របស់ដើមបណ្តឹងរដ្ឋប្បវេណី[១]

ភាសាដើម : ខ្មែរ

ប្រភេទឯកសារ : សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 02 / 2008
ម៉ោង (Time/Heure): 11:50 AM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

## សារណា

## វត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងគ្រប់ដំណាក់កាលនីតិវិធី

---

អ្នកដាក់ឯកសារ :

មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី
លោកមេធាវី ហុង គីមសួន
លោកមេធាវី ឡោ ជុនធី
លោកមេធាវី យុង ផានិត
លោកមេធាវី នី ចាន់ឌី

អ្នកទទួលឯកសារ :

ចៅក្រមនៃអង្គបុរេជំនុំជម្រះ
លោកចៅក្រម ប្រាក់ គីមសាន
លោកចៅក្រម Rowan DOWNING
លោកចៅក្រម ន័យ ថុល
លោកចៅក្រម Katinka LAHUIS
លោកចៅក្រម ហួត វុទ្ធី

សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 25 / 02 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

(១)ដើមបណ្តឹងរដ្ឋប្បវេណី មិនបញ្ចេញឈ្មោះ ដែលបានដាក់ពាក្យជូនសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ ២០០៨ តាមរយៈការិយាល័យការពារជនរងគ្រោះ ។

00164703

C11/43

## ក. សេចក្តីផ្តើម

សហមេធាវីជនត្រូវចោទ **នួន ជា** តវ៉ាពីការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាលពីថ្ងៃទី ៧-៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដោយជំទាស់មិនចង់ឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមាននៅក្នុងសវនាការ ។ ប៉ុន្តែ សហមេធាវីការពារជនត្រូវចោទមិនបានជំទាស់នឹងវត្តមានរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីក្នុងអង្គជំនុំជំរះជាទូទៅនោះទេ ហើយក៏មិនបញ្ជាក់ថា វិធានផ្ទៃក្នុងរបស់អង្គជំនុំជំរះបានរារាំងមិនឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមានដែរ ដោយគ្រាន់តែលើកឡើងថាវិធានផ្ទៃក្នុងមិនចែងឱ្យបានច្បាស់ ។ ពួកគេក៏បានលើកឡើងដែរថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាមុនចូលសវនាការ មិនបញ្ជាក់ពីផលប្រយោជន៍នៃការចូលរួម និង យល់ថាអាចប៉ះពាល់ដល់សិទ្ធិទទួលបាននូវសវនាការដោយយុត្តិធម៌តែប៉ុណ្ណោះ ។

សហមេធាវីជនត្រូវចោទក៏បានលើករឿងក្តីមួយនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺរឿងក្តី Thomas Lubanga Dyilo ជាយុត្តិសាស្ត្រ ដើម្បីអង្គជំនុំជំរះវិសាមញ្ញអនុវត្តតាម ។ ប៉ុន្តែ ខ្លឹមសារនៃលក្ខន្តិកៈក្រុងរ៉ូម និង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាវាខុសគ្នា ។ តាមលក្ខន្តិកៈក្រុងរ៉ូមជនរងគ្រោះគ្រាន់តែមានសិទ្ធិចូលរួមក្នុងដំណើរការកាត់ក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនមែនក្នុងឋានៈជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ រីឯក្នុងអង្គជំនុំជំរះវិសាមញ្ញវិញ ជនរងគ្រោះអាចចូលរួមក្នុងឋានៈជាជនរងគ្រោះក៏បាន ឬ ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក៏បាន ។ នៅពេលដែលពួកគេចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ពួកគេត្រូវមានសិទ្ធិដូចគ្នានឹងភាគីផ្សេងៗទៀតដែរ ។

## ខ. ប្រវត្តិដំណើរការនីតិវិធី

១. យោងទៅតាមវិធាន ២១ នៃ បទបញ្ជាផ្ទៃក្នុង ជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងឋានៈជា ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងករណីរឿង នួន ជា នៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០០៨ ។ ថ្ងៃនោះជាថ្ងៃសុក្រ ជាថ្ងៃចុងសប្តាហ៍ ហើយដែលថ្ងៃច័ន្ទជាថ្ងៃសវនាការតែម្តង ។ ដោយសារពេលវេលាដ៏ខ្លីនេះ មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី បានទទួលដំណឹងពីសវនាការយ៉ាងបន្ទាន់ ប៉ុន្តែដើម្បីយុត្តិធម៌ដល់ជនរងគ្រោះ មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួម និង មិនជំទាស់ដល់នីតិវិធីរបស់តុលាការនោះទេ ។

២. អង្គបុរេជំនុំជំរះ បានបន្តសវនាការរបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីរបស់ នួន ជា ជំទាស់ទៅនឹងការឃុំខ្លួនបណ្តោះអាសន្នតទៅទៀតនៅថ្ងៃទី ៧-៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។

៣. ក្នុងសវនាការ សហមេធាវីជនត្រូវចោទបានលើកឡើងថា ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការជំទាស់ការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ គឺជាការរំលោភសិទ្ធិទទួលសវនាការដោយយុត្តិធម៌ ។ ពួកគេបានលើកឡើងថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណារបស់ខ្លួន និង មិនបានបង្ហាញពីផលប្រយោជន៍របស់ខ្លួនក្នុងការចូលរួមសវនាការនោះទេ ។ ថែមពីនេះទៅទៀត សហមេធាវីជនត្រូវចោទបានលើកឡើងថា វិធាន ២៣ នៃ អង្គជំនុំជំរះវិសមញ្ញមិនបានផ្តល់សិទ្ធិភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលរួមសវនាការឧទ្ធរណ៍នឹងការសំរេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ។ គេក៏បានលើកឡើងផងដែរថា អ្វីដែលគេលើកឡើងគឺដូចគ្នានឹងករណី Prosecutor v. Thomas Lubanga Dyilo នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

៤. អង្គបុរេជំនុំជំរះ ជូនដំណឹងមួយនៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដល់គ្រប់ភាគី និង សាធារណៈជនឱ្យដាក់សារណាដែលពាក់ព័ន្ធនឹងការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ ។

## គ. សេចក្តីថ្លែងការណ៍

១. <u>ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងគ្រប់ដំណាក់ការនៃនីតិវិធីរបស់តុលាការកម្ពុជា</u> :

នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដូចជាប្រព័ន្ធច្បាប់ប្រទេសដែលប្រើប្រព័ន្ធច្បាប់ស៊ីវិលផ្សេងទៀតដែរ ជនរងគ្រោះមានសិទ្ធិចូលខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងរដ្ឋប្បវេណីពីជនត្រូវចោទ [២] ។ នៅពេលដែលជនរងគ្រោះតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខ្លួនគេត្រូវក្លាយជាភាគីមួយនៃរឿងក្តី និង មានសិទ្ធិដូចជាភាគីផ្សេងទៀតដែរ ។

ក្នុងមាត្រា ២៥៩-២៦០ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ គូភាគី ពោលគឺ ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីរបស់ខ្លួន អាចប្រគល់សារណាជូនតុលាការរហូតដល់ពេលចាប់ផ្តើមបើកសវនាការ និងក្រោយពីរបាយការណ៍របស់ប្រធានសភាស៊ើបសួរ [៣] មេធាវីរបស់គូភាគីអាចធ្វើការកត់សំគាល់របស់ខ្លួន បន្ទាប់ពីអគ្គព្រះរាជអាជ្ញាធ្វើការកត់សំគាល់រួចហើយ ។

[២] មាត្រា ២២ ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧ ។

[៣] ប្រៀបប្រដូចទៅនឹងអង្គបុរេជំនុំជំរះនៃអង្គជំនុំជំរះវិសមញ្ញក្នុងតុលាការកម្ពុជាដែរ ។

មាត្រា ២៥៩ ក្រមនីតិវិធីព្រហ្មទណ្ឌ : ការពិគ្រោះសំណុំរឿង និង សារណា

..............................

**គូភាគី** និង **មេធាវី** អាចប្រគល់សារណាដល់ក្រឡាបញ្ជី ។

សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និង សារណាត្រូវចុះទិដ្ឋាការដោយក្រឡាបញ្ជី ដោយមានការចុះកាល បរិច្ឆេទ និង ត្រូវបញ្ចូលក្នុងសំណុំរឿងភ្លាម ។

គូភាគី និង មេធាវី ត្រូវបានអនុញ្ញាតឱ្យជូនសារណារហូតដល់ពេលចាប់ផ្តើមបើកសវនាការ ។

មាត្រា ២៦០ ក្រមនីតិវិធីព្រហ្មទណ្ឌ : ដំណើរការនៃកិច្ចពិភាក្សាដេញដោល

......................

ក្រោយពីរបាយការណ៍របស់ប្រធានសភាស៊ើបសួរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង មេធាវីរបស់គូភាគី ធ្វើការកត់សំគាល់របស់ខ្លួនដោយសង្ខេប ។..................

បើនិយាយពីរឿងក្តីជាក់ស្តែងវិញ មានឧទាហរណ៍ច្រើនណាស់ ដែលមានមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី ចូលខ្លួនធ្វើការតវ៉ាក្នុងសវនាការ ។

ជាឧទាហរណ៍ :

ដូចជារឿងក្តីឃាតកម្មលើរូបលោកជាវិជ្ជា ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ១៧០ ចុះថ្ងៃទី ១៦ មិនា ឆ្នាំ ២០០៤ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រីមេធាវី ពឹង យក់ហៀប មានវត្តមាន ក្នុងសវនាការ សាលាឧទ្ធរណ៍វិនិច្ឆ័យលើពាក្យបណ្តឹងតវ៉ានឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ជនជាប់ចោទ ប៊ិន សំណាង និង សុខ សំអឿន ។

ក្នុង សំណុំរឿង ព្រហ្មទណ្ឌលេខ ៦៩៦ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៦, ជនជាប់ចោទឈ្មោះ ទៀង នី គេទ ប្រុស ត្រូវបានតុលាការខេត្តកំពង់ឆ្នាំងអនុញ្ញាតិឱ្យនៅក្រៅឃុំ តាមដីកាលេខ ៩៩២ ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០៥ តែការដោះលែងឱ្យនៅក្រៅឃុំត្រូវបានប្តឹងឧទ្ធរណ៍មកសាលាឧទ្ធរណ៍ ។ នៅក្នុងសវនាការសាលាឧទ្ធរណ៍ពិចារណាលើការប្តឹងឧទ្ធរណ៍នេះ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺ លោកស្រីមេធាវី ស៊ិន សុវន ក៏មានវត្តមាននៅក្នុងសវនាការពេលនោះដែរ និង បានធ្វើការតវ៉ា ធ្វើការកត់សំគាល់ ដូចជាក្នុងដំណាក់ការនានាដែរ ។

ដូចនេះអាចបង្ហាញឱ្យឃើញថា ក្នុងតុលាការកម្ពុជា ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមគ្រប់ដំណាក់ការ នៃនីតិវិធីរបស់តុលាការ និង មានសិទ្ធិអ្វីៗដូចជាភាគីផ្សេងទៀតផងដែរ ។

00164706

C11/43

២. ច្បាប់កម្ពុជាពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតែជាអាទិភាព :

យោងទៅតាមមាត្រា ៣៣ នៃ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជំរះវិសមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ ២០០៤ អង្គជំនុំជំរះវិសមញ្ញត្រូវប្រព្រឹត្តទៅតាមនីតិវិធីជាធរមានរបស់កម្ពុជា លើកលែងតែនីតិវិធីដែលមានស្រាប់នោះ ពុំបានចែងពីករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្ត ឬ ប្រសិន បើមានលក្ខណៈផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ ទើបគេត្រូវស្វែងរកការណែនាំក្នុងបទដ្ឋានដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិផ្សេងទៀត ។

ប៉ុន្តែក្នុងករណីភាគីដើមបណ្តឹងរដ្ឋប្បវេណី ច្បាប់កម្ពុជាបានចែងយ៉ាងច្បាស់ ពីអត្ថិភាព វត្តមានរបស់ខ្លួនក្នុងគ្រប់ដំណាក់ការនីតិវិធី និង អាចធ្វើការកត់សំគាល់របស់ខ្លួនក្នុងសវនាការនានាបាន ។ បើនិយាយពីបទដ្ឋានអន្តរជាតិវិញ មានប្រព័ន្ធច្បាប់ប្រទេសជាច្រើន ដូចជា ប្រព័ន្ធច្បាប់ប្រទេសបារាំងជាដើម ដើមបណ្តឹងរដ្ឋប្បវេណីក៏មានសិទ្ធិ ដូចជាក្នុងប្រព័ន្ធច្បាប់កម្ពុជាដែរ ហើយបើទោះជាក្នុងលក្ខន្តិកៈក្រុងរ៉ូមក្តី ក៏មិនមានខបញ្ញត្តិណាមួយ ដែលចែងថាការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីគឺជាការរំលោភសិទ្ធិរបស់ភាគីណាមួយ ហើយដែលត្រូវហាមឃាត់ដាច់ខាតមិនឱ្យមានវត្តមានក្នុងនីតិវិធីរបស់តុលាការនោះទេ ។ ដូចនេះ គឺមានន័យថា ច្បាប់កម្ពុជាគ្រង់សិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិនោះទេ ហើយមានន័យច្បាស់លាស់ ដែលត្រូវតែនៅជាធរមានសំរាប់អង្គជំនុំជំរះវិសមញ្ញអនុវត្តដដែល ។

ដូច្នេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែមានសិទ្ធិចូលរួមគ្រប់ដំណាក់ការនៃនីតិវិធី រួមទាំងគ្រប់សវនាការរបស់អង្គបុរេជំនុំជំរះផង ។

៣. វត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនរំលោភលើសិទ្ធិរបស់ជនត្រូវចោទនោះទេ :

នៅក្នុងសវនាការរឿងការដោះលែងក្រៅឃុំបណ្តោះអាសន្ន នាថ្ងៃទី ៧-៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ សហមេធាវីរបស់ជនត្រូវចោទបានលើកឡើងថាការអនុញ្ញាតឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី ឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនេះ គឺជាការរំលោភលើសិទ្ធិទទួលបាននូវការជំនុំជំរះក្តីដោយយុត្តិធម៌នៃជនត្រូវចោទ ។

នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីគឺជាសិទ្ធិ ដែលចែងដោយច្បាប់ ។ សហមេធាវីជនត្រូវចោទក៏បានទទួលស្គាល់ផងដែរថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីផ្សេងៗ ហើយជំទាស់វត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណីតែក្នុងសវនាការឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ ។ ប្រសិនបើការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការជំទាស់ការឃុំខ្លួនបណ្តោះអាសន្ន វាពិតជារំលោភលើសិទ្ធិទទួល

បានការជំនុំជំរះដោយយុត្តិធម៌មែននោះ ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីផ្សេងទៀតក៏វាត្រូវរំលោភសិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌ដូចគ្នាដែរ ។ ដូចនេះ ការលើកឡើងនេះវាមិនសមហេតុផលនោះទេ ។

ម្យ៉ាងវិញទៀត ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងតុលាការកម្ពុជា គឺជាការអនុវត្តសិទ្ធិដែលធានាដោយច្បាប់ មិនមែនជាការរំលោភលើសិទ្ធិរបស់ជនត្រូវចោទនោះទេ ។

ដែលហៅថាសិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌ត្រូវបានរំលោភ លុះត្រាតែសិទ្ធិជាក់លាក់ណាមួយត្រូវបានរំលោភ ដូចជា សិទ្ធិមានមេធាវី សិទ្ធិបង្ហាញភស្តុតាង សិទ្ធិសួរតទល់ សិទ្ធិធ្វើការកត់សំគាល់ ។ល។ ក៏ប៉ុន្តែវត្តមានភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការនៃអង្គបុរេជំនុំជំរះ មិនបានប៉ះពាល់ដល់សិទ្ធិជាក់លាក់ណាមួយរបស់ជនត្រូវចោទនោះឡើយ ហើយសហមេធាវីជនត្រូវចោទក៏មិនបានលើកពីសិទ្ធិជាក់លាក់ណាមួយដែលត្រូវបានរំលោភផងដែរ ។

៤. <u>ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី មិនចាំបាច់ទាល់តែមានផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ</u> :

ពិតមែនហើយថា នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ជនរងគ្រោះអាចធ្វើការកត់សំគាល់នៅក្នុងសវនាការបាន លុះត្រាតែការកត់សំគាល់នោះមានផលប្រយោជន៍ផ្ទាល់ខ្លួន ក៏ប៉ុន្តែនោះគឺជានីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលអនុញ្ញាតិឱ្យជនរងគ្រោះគ្រាន់តែមានសិទ្ធិចូលរួមតែប៉ុណ្ណោះ មិនមែនក្នុងនាមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីដូចក្នុងអង្គជំនំជំរះវិសមញ្ញ និង តុលាការកម្ពុជានោះទេ ។

នៅក្នុងច្បាប់កម្ពុជា ច្បាប់បង្កើតអង្គជំនុំជំរះវិសមញ្ញ និង វិធានផ្ទៃក្នុងនៃអង្គជំនុំជំរះវិសមញ្ញក្នុងតុលាការកម្ពុជា មិនមានតម្រូវថា ជនរងគ្រោះ ដែលអាចចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីបាន លុះត្រូវតែបង្ហាញថាអ្វី ដែលខ្លួនលើកឡើង ឬ ធ្វើការកត់សំគាល់ត្រូវតែមានផលប្រយោជន៍ផ្ទាល់ខ្លួនដូចជាលក្ខន្តិកៈក្រុងរ៉ូមនោះទេ ។

សហមេធាវីជនត្រូវចោទបានលើកយកករណីរបស់ Thomas Lubanga Dyilo ក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយបានសង្កត់ចំណុច ដែលសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានសំរេចនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ បដិសេធនការចូលរួមរបស់ជនរងគ្រោះ ។

ការលើកយកយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីបង្ខំឱ្យអង្គជំនុំជំរះវិសមញ្ញអនុវត្តតាមគឺជាការយល់ច្រឡំ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ និង អង្គជំនុំជំរះវិសមញ្ញ គឺមានវិធាន និង នីតិវិធីខុសពីគ្នា ។ យោងទៅតាមលក្ខន្តិកៈក្រុងរ៉ូម តុលាការព្រហ្មទណ្ឌអន្តរជាតិទទួលស្គាល់ជនរងគ្រោះក្នុងឋានៈជាអ្នកចូលរួមតែប៉ុណ្ណោះ ហើយផ្តល់សិទ្ធិត្រឹមបញ្ចេញទស្សនៈ និង បង្ហាញពីកង្វល់របស់ខ្លួននៅក្នុងនីតិវិធីតែប៉ុណ្ណោះ ។ ចំណុចនេះ វាខុសគ្នា

00164708

C11/43

ទៅនឹងគោលការណ៍របស់អង្គជំនុំជំរះវិសាមញ្ញ ដែលត្រូវប្រកាន់ច្បាប់កម្ពុជាជាធរមាន ហើយដែលអនុញ្ញាតឱ្យជនរងគ្រោះអាចចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលមានសិទ្ធិច្រើនជាងជនរងគ្រោះនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

មាត្រា ៦៨(៣) នៃ លក្ខន្តិកៈក្រុងរ៉ូមដែលចែងពីការចូលរួមរបស់ជនរងគ្រោះ :

កាលណាប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះត្រូវប៉ះពាល់ តុលាការត្រូវអនុញ្ញាតឱ្យគេបញ្ចេញ បង្ហាញ និង ត្រូវបានពិចារណានូវទស្សនៈ និង កង្វល់របស់គេ នៅក្នុងដំណាក់កាលនានានៃដំណើរការជំរះរឿងក្តី ដែលត្រូវតុលាការបានកំណត់ថាសមស្រប និង នៅក្នុងលក្ខណៈមួយដែលមិនមានលក្ខណៈអគតិ ឬ មិនមានលក្ខណៈមិនស្របជាមួយសិទ្ធិរបស់ជនត្រូវចោទ និងការជំនុំជំរះដោយយុត្តិធម៌ និង ឥតលំអៀង ។ ទស្សនៈ និង កង្វល់នោះ អាចត្រូវបង្ហាញ ដោយអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ពេលដែលតុលាការពិចារណាយល់ឃើញថាសមស្រប អនុលោមតាមវិធាន និង នីតិវិធីនៃភស្តុតាង ។

ដូចនេះ សិទ្ធិរបស់ជនរងគ្រោះក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ មានការកំរិតព្រំដែន ដោយសារពួកគេមិនមែនចូលរួមក្នុងឋានៈជាភាគីដូចជា ភាគីជនត្រូវចោទ និង ព្រះរាជអាជ្ញានោះទេ ។ ប៉ុន្តែ សិទ្ធិរបស់គេត្រូវពឹងផ្អែកទៅលើការសំរេចរបស់តុលាការ ដែលអាចអនុញ្ញាតឱ្យចូលរួមបានដើម្បីបញ្ចេញទស្សនៈ និង បង្ហាញពីការកង្វល់របស់ខ្លួនទៅតុលាការតែប៉ុណ្ណោះ ។

តួនាទីរបស់ជនរងគ្រោះក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចតម្រូវឱ្យអង្គជំនុំជំរះវិសាមញ្ញយកតាមនោះទេ ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់បង្ហាញពីផលប្រយោជន៍នៃការចូលរួមរបស់ខ្លួន មិននឹងត្រូវអនុញ្ញាតឱ្យចូលរួមនោះទេ ។

ដោយកម្ពុជាចម្លងក្រមនីតិវិធីពីប្រព័ន្ធបារាំង ប្រព័ន្ធកម្ពុជា គឺជាប្រព័ន្ធស៊ីវិល ដែលអាចអនុញ្ញាតឱ្យជនរងគ្រោះចូលរួមក្នុងឋានៈជាភាគីមួយនៃនីតិវិធីព្រហ្មទណ្ឌ ។ ក្នុងប្រព័ន្ធនេះ ជនរងគ្រោះមានសិទ្ធិនឹងចូលរួមពេញលេញក្នុងគ្រប់ដំណើរការនីតិវិធីរបស់តុលាការ មិនដូចជាការចូលរួមរបស់ជនរងគ្រោះក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនោះទេ ។ តែទោះជាយ៉ាងណា សិទ្ធិរបស់ជនជាប់ចោទក្នុងប្រព័ន្ធទាំងពីរនេះគឺមានដូចគ្នា ។

៥. <u>ការដាក់សារណារបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាកាតព្វកិច្ចនោះទេ ក្នុងច្បាប់កម្ពុជា</u> :

នៅក្នុងសវនាការរឿងការដោះលែងក្រៅឃុំបណ្តោះអាសន្ន នាថ្ងៃទី ៧-៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ សហមេធាវីរបស់ជនត្រូវចោទបានលើកយកចំណុច ដែលមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាជូនដល់អង្គបុរេជំនុំជំរះ ជាមូលហេតុសុំមិនឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលរួមសវនាការនៅពេលនោះ ។

00164709

C11/43

ដូចដែលបានបញ្ជាក់កន្លងមកហើយថា កាលបើច្បាប់កម្ពុជាមានន័យច្បាស់លាស់ និង មិនផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិដែលនាំមានការរំលោភសិទ្ធិដែលធានាដោយច្បាប់អន្តរជាតិណាមួយនោះទេនោះ ច្បាប់កម្ពុជានៅតែមានសុពលភាពតម្រូវឱ្យអង្គជំនុំជំរះវិសមញ្ញត្រូវតែអនុវត្តតាមតទៅទៀតនោះ ។

នៅក្នុងច្បាប់កម្ពុជា ការដាក់សារណា ឬ មិនដាក់សារណា មិនមែនជាតម្រូវការចាំបាច់ ដែលកាលបើមិនដាក់សារណានាំឱ្យភាគីដែលមិនដាក់ត្រូវបាតបង់សិទ្ធិចូលរួមនោះទេ ។ មាត្រា ២៥៩ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ វាក្យខ័ណ្ឌ ៣ ចែងថា "គូភាគី និង មេធាវី អាចដាក់សារណាដល់តុលាការ "។ គ្មានមាត្រាណាមួយ នៃ ច្បាប់កម្ពុជាតម្រូវថា កាលណាគូភាគីណាមួយមិនដាក់សារណារបស់ខ្លួន ភាគីនោះនឹងត្រូវបាត់បង់សិទ្ធិចូលរួមសវនាការ ឬ នីតិវិធីរបស់តុលាការនោះទេ គ្រាន់តែនឹងត្រូវបាត់បង់ឱកាសបង្ហាញពីគោលជំហររបស់ខ្លួន ដល់ក្រុមប្រឹក្សាជំនុំជំរះជាមុនតែប៉ុណ្ណោះ ។ ទោះជា ភាគីជនត្រូវចោទមិនដឹងជាមុននូវជំហររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏វាមិនប៉ះពាល់សិទ្ធិរបស់ជនត្រូវចោទនោះដែរ ។

ដូចនេះ ការស្នើសុំរបស់សហមេធាវីជនត្រូវចោទដើម្បីសុំឱ្យអង្គបុរេជំនុំជំរះដកសិទ្ធិចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសវនាការជំទាស់នឹងការដាក់ឱ្យជនត្រូវចោទជាប់នៅក្នុងឃុំបណ្តោះអាសន្នជាការមិនត្រឹមត្រូវនោះទេ ហើយក៏មិនប៉ះពាល់ដល់សិទ្ធិទទួលបានសវនាការដោយយុត្តិធម៌របស់ជនត្រូវចោទនោះដែរ ។ ផ្ទុយទៅវិញ ការផ្តល់សិទ្ធិពេញលេញដល់ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីរបស់ខ្លួន ចូលរួមគ្រប់ដំណើរការនីតិវិធីតុលាការ ដូចដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និង វិធានផ្ទៃក្នុងនៃអង្គជំនុំជំរះវិសមញ្ញរឹតតែធ្វើឱ្យប្រាកដថា សិទ្ធិ និង ផលប្រយោជន៍របស់ភាគីទាំងអស់អស់ត្រូវបានការពារ និង បានធានាទៅវិញទេ ។

៦. <u>សិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងអង្គជំនុំជំរះវិសាមញ្ញគាំទ្រដោយវិធានផ្ទៃក្នុង</u> :

ក្នុងវិធាន ២៣ ត្រង់ចំណុច ១ក បានចែងថា គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជំរះវិសាមញ្ញ គឺដើម្បីចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នក ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជំរះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ ។ ពាក្យថាចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជំរះវិសាមញ្ញ គឺមានន័យថា មានសិទ្ធិធ្វើអ្វីៗទាំងអស់ដូចជាភាគីផ្សេងទៀត ភាគីសហព្រះរាជអាជ្ញា ភាគីជនជាប់ចោទ ផងដែរ ។

ក្នុងវិធាន ២៣ ដដែលត្រង់ចំណុច ៦ក បានចែងថា នៅពេលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះក្លាយជាភាគីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ។ មាត្រា ៧៣(ក) ៧៣(ខ) និង ៧៤(៤) បានផ្តល់សិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិប្តឹងឧទ្ធរណ៍ជាច្រើន ។ មាត្រា ៧៧(៤) មេធាវីភាគីអាចសុំមើលសំណុំរឿងរហូតដល់ថ្ងៃ

សវនាការ ។ ដូចនេះ បើយោងទៅតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជំរះវិសមញ្ញ ភាគីទាំងអស់ រួមទាំងភាគីដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិចូលរួមក្នុងសវនាការឧទ្ធរណ៍របស់អង្គបុរេជំនុំជំរះ ដោយមិនចាំបាច់សុំការអនុញ្ញាតិឱ្យចូលរួមជាមុននោះទេ ។

ទាំងអស់នេះរឹតតែបង្ហាញឱ្យឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី ក៏ជាភាគីមួយនៃ ភាគីផ្សេងទៀត ដូចជា សហព្រះរាជអាជ្ញា និង ជនត្រូវចោទដែរ ។ ពោលគឺ **ដើមបណ្តឹងរដ្ឋប្បវេណី** និង ភាគីផ្សេងទៀត ត្រូវតែមានសិទ្ធិដូចគ្នា ។

## គ. សន្និដ្ឋាន

សរុបសេចក្តីមក ភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីមួយនៃអង្គជំនុំជំរះ មេធាវីការពារជនត្រូវចោទជាអ្នកការពារផលប្រយោជន៍ឱ្យជនត្រូវចោទ សហព្រះរាជអាជ្ញាជាអ្នកការពារផលប្រយោជន៍សាធារណៈ ឯ ភាគីដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកការពារផលប្រយោជន៍ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ហើយត្រូវតែមានសិទ្ធិអំណាចចូលរួមក្នុងគ្រប់តំណាក់កាលនីតិវិធី និង ស្មើគ្នាដូចជាភាគីផ្សេងទៀតនោះដែរ ។

## ឃ. សំណូមពរ

ភាគីដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើសំណូមពរដល់អង្គបុរេជំនុំជំរះ នៃ អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការ កម្ពុជា ចេញនូវសាលដីកាមួយ បដិសេធការទាមទាររបស់ភាគីជនត្រូវចោទ ។

ធ្វើនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨
មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី

មេធាវី ហុង គឹមសួន  មេធាវី យុង ផានិត  មេធាវី ឡោ ជុនធី  មេធាវី នី ចាន់ឌី